ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្តសៀមរាប**
លេខ: ៦៤៣/១៧ ស.ល

# ជម្រាបជូន
## លោកអភិបាល នៃគណៈអភិបាលស្រុកប្រាសាទបាគង
## ស្រុកក្រឡាញ់ ស្រុកស្រីស្នំ ស្រុកស្វាយលើ និងស្រុកវ៉ារិន

**កម្មវត្ថុ** : សំណើសុំអញ្ជើញចូលរួម និងចាត់តាំងនាយករដ្ឋបាលស្រុក និងសមាជិកក្រុមប្រឹក្សាឃុំ ដែលសកម្ម ចំនួន០១រូប ដើម្បីចូលរួមសិក្ខាសាលាចាប់ផ្តើមគម្រោង "ការកាត់បន្ថយភាពងាយរងគ្រោះនៃជីវភាព របស់ប្រជាជនកម្ពុជានៅជនបទ តាមរយៈការពង្រឹងផែនការ ប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងអនុវត្តសកម្មភាពអាទិភាព (SRL)" ។

**យោង** : លិខិតលេខ ១៨៩ សណ/គ.ជ.អ.ប ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧ របស់លេខាធិការដ្ឋាន គ.ជ.អ.ប។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោកអភិបាល** ជ្រាបថា ៖ នាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនឹងរៀបចំសិក្ខាសាលាចាប់ផ្តើមគម្រោង "ការកាត់បន្ថយភាពងាយរងគ្រោះនៃជីវភាព របស់ប្រជាជនកម្ពុជានៅជនបទ តាមរយៈការពង្រឹងផែនការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងអនុវត្តសកម្មភាពអាទិភាព (SRL)" ដើម្បីបង្ហាញពីគម្រោង និងពិភាក្សាអំពីសកម្មភាពការងារដែលត្រូវអនុវត្ត ដោយសិក្ខាសាលានេះនឹងប្រព្រឹត្តទៅ នៅថ្ងៃទី២៧-២៨ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង ៧:៣០ នាទីព្រឹក នៅសណ្ឋាគារ អង្គរប៉ារ៉ាឌី ខេត្តសៀមរាប។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកអភិបាលស្រុក** មេត្តាអញ្ជើញចូលរួម និងចាត់តាំងនាយករដ្ឋបាលស្រុក និងសមាជិកក្រុមប្រឹក្សាឃុំដែលសកម្ម ០១រូប ដើម្បីចូលរួមក្នុងសិក្ខាសាលានេះ តាមកាលបរិច្ឆេទ និងទីកន្លែងខាងលើតាមការគួរ។ ចំពោះប្រាក់បេសកកម្ម និងថ្លៃធ្វើដំណើររបស់អ្នកចូលរួម ជាបន្ទុករបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។

សូម **លោកអភិបាល** ទទួលនូវការស្រឡាញ់រាប់អានដ៏ស្មោះ ពីខ្ញុំ ។

សៀមរាប ថ្ងៃទី២៣ ខែ មីនា ឆ្នាំ២០១៧
**ជ. អភិបាលខេត្ត**
**អភិបាលរង**

**ពិន ប្រាកដ**

លេខទូរស័ព្ទទំនាក់ទំនង:
-លោក ទិព្វ ពិសិទ្ធ: ០១៧ ៦៦៥ ៩៥៤

សាលាខេត្តសៀមរាប ផ្លូវ៦០ម៉ែត្រ ភូមិបឹងដូនប៉ា សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប Siem Reap Provinceial Hall, 60m Street, Boeng Donpa Village, Sangkat Slorkram, Siem Reap Municipality, Siem Reap Province. E-mail: srphall@yahoo.com Tel: (855) 63 765 276, (855) 63 765 319, Fax:(855) 63 765 343